**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៤៦ អនក្រ.បក

# អនុក្រឹត្យ

# ស្តីពី

# ការធ្វើអនុបយោគដីព្រៃបម្រុងទុកអចិន្ត្រៃយ៍របស់រដ្ឋ សម្រាប់សម្បទានដីសង្គមកិច្ច រៀបចំបង្កើតជាភូមិសែនមនោរម្យ ១ និង ភូមិសែនមនោរម្យ ២ ស្ថិតនៅក្នុងឃុំគោកមន ស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/ ០៩០៨/ ១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល

-បានឃើញព្រះរាជក្រមលេខ នស/ រកម/ ០៨០២/០១៦ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីព្រៃឈើ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៧ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាល នៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈ

-បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈ

-បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

-បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០៣ ស្តីពីសម្បទានដីសង្គមកិច្ច
-បានឃើញអនុក្រឹត្យលេខ ១១៨ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ តុលា ឆ្នាំ ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
-យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា ១ :**

ត្រូវបានចាត់ថ្នាក់ជាផ្ទៃដីព្រៃសម្រាប់ផ្ទេរ ដើម្បីគោលបំណងអភិវឌ្ឍផ្សេងទៀត នូវដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍របស់រដ្ឋ មានទំហំសរុប ៩៩៧ ហិកតា ស្ថិតក្នុងឃុំគោកមន ស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ ដូចមានផែនទីជូនភ្ជាប់ជាឧបសម្ព័ន្ធនៃអនុក្រឹត្យ ហើយកំណត់ដោយបណ្តុំចំណុចគោលដែលមាននិយាមកាដូចខាងក្រោម :

ភូមិសែនមនោរម្យ ១ មានផ្ទៃដី ៥០២ ហិកតា

| | | |
|---|---|---|
| A (៣២៤៥៩៤, ១៥៨៥៤០០) | B (៣២៥០៥៥, ១៥៨៥៣៤៤) | C (៣២៥៩៣៦, ១៥៨៥៦៣៨) |
| D (៣២៦៥៦៧, ១៥៨៥៤៦១) | E (៣២៩៣២៧, ១៥៨៤៩៩២) | F (៣២៥៩៧៣, ១៥៨៤០២៣) |
| G (៣២៦៧១៣, ១៥៨៤៤៦៥) | H (៣២៤៣៥៦, ១៥៨៤៣៧០) | I (៣២៤៦៦៧, ១៥៨៥២០៧) |
| J (៣២៤៥៩២, ១៥៨៥០១០) | K (៣២៤៤៥៦, ១៥៨៤៨៥៥) | L (៣២៤៤៥៥, ១៥៨៤៦៧៥) |
| M (៣២៤៣៩៦, ១៥៨៤៥១៣) | | |

ភូមិសែនមនោរម្យ ២ មានផ្ទៃដី ៤៩៥ ហិកតា

| | | |
|---|---|---|
| N (៣២៤៣១៦, ១៥៨៤៣៧៣) | O (៣២២៦១៤, ១៥៨៤៧៧០) | P (៣២០០២០, ១៥៨៤៧៧០) |
| Q (៣២០០២០, ១៥៨៥៩០៧) | R (៣២០៨៧២, ១៥៨៦០៩៦) | S (៣២២៥៩៨, ១៥៨៥៧៨២) |
| T (៣២៤៣៧៦, ១៥៨៥៣៩៨) | U (៣២៤៥៥៧, ១៥៨៥៣៩៨) | |

**មាត្រា ២ :**

ត្រូវបានធ្វើអនុបយោគផ្ទៃដីទំហំ ប្រាំបួនរយកៅសិបប្រាំពីរហិកតា (៩៩៧ ហិកតា) ដូចមានចែងក្នុងមាត្រា ១ នៃអនុក្រឹត្យនេះ ដែលជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ មកជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ។

**មាត្រា ៣ :**

ត្រូវបានប្រគល់អាណត្តិកាន់កាប់ដីឯកជនរបស់រដ្ឋទំហំ ប្រាំបួនរយកៅសិបប្រាំពីរហិកតា (៩៩៧ ហិកតា) ដូចមានចែងក្នុងមាត្រា ២ នៃអនុក្រឹត្យនេះ ប្រគល់ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ជាអាជ្ញាធរកាន់កាប់ដីរដ្ឋដើម្បីចុះបញ្ជីជាដីឯកជនរបស់រដ្ឋ សម្រាប់បែងចែកជាសម្បទានដីសង្គមកិច្ចជូនគ្រួសារយោធិន និងនគរបាល រៀបចំបង្កើតជាភូមិសែនមនោរម្យ ១ និង ភូមិសែនមនោរម្យ ២ ស្ថិតក្នុងឃុំគោកមន ស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ ស្របតាមគោលការណ៍កំណត់របស់រាជរដ្ឋាភិបាល និង តម្រូវការជាក់ស្តែង ។

**មាត្រា ៤ :**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៥ :**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និង អភិបាលខេត្តឧត្តរមានជ័យ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ [illegible] ឆ្នាំ២០១០

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
-ដូចមាត្រា ៥
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ៥៦៧ អនក្រ.បក ចុះថ្ងៃទី ០៤ ខែ ៨៧ ឆ្នាំ ២០១០

## ស្តីពីការធ្វើអនុបយោគដីព្រៃលិចទឹកនិងព្រៃស្រោងទឹកត្រូវលិចដោយសារទឹកភ្លៀងរបស់រដ្ឋ សម្រាប់សម្បទានដីសង្គមកិច្ច វៀបចំបង្កើតជា
## ភូមិសែនមនោរម្យ ១ និង ភូមិសែនមនោរម្យ ២ ស្ថិតនៅក្នុងឃុំគោកមន ស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ




**សញ្ញាសំគាល់**

- ● ចំណុចគោល
- ▭ ព្រំប្រទល់សម្បទានដីសង្គមកិច្ច

N W E S

មាត្រដ្ឋាន ១:៥០ ០០០

0 0.5 1 2Km

| ភូមិសែនមនោរម្យ ១ | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| A | 324594 | 1585400 | D | 326567 | 1585461 | G | 326713 | 1584465 | J | 324592 | 1585010 |
| B | 325055 | 1585344 | E | 329327 | 1584992 | H | 324356 | 1584370 | K | 324496 | 1584855 |
| C | 325936 | 1585638 | F | 329973 | 1584023 | I | 324667 | 1585207 | L | 324455 | 1584675 |
| | | | | | | | | | M | 324396 | 1584513 |
| **ភូមិសែនមនោរម្យ ២** | | | | | | | | | | | |
| N | 324316 | 1584373 | P | 320020 | 1584770 | R | 320872 | 1586096 | T | 324376 | 1585398 |
| O | 322614 | 1584770 | Q | 320020 | 1585907 | S | 322598 | 1585782 | U | 324557 | 1585398 |